BMI0140

# សម្ភាសជាមួយឈ្មោះ លីម សារ៉េម ភេទស្រី អាយុ៥៣ឆ្នាំ

## មុខងារខ្មែរក្រហមៈ កងចល័តទំនប់ត្រពាំងថ្ម

## មរស់នៅភូមិដើង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ ឡុង ដានី

០០:៥១:២៩

២៤ទំព័រ

ដានី ៖ ជំបូងមីងខ្ញុំចង់ស្គាល់ឈ្មោះមីង ឈ្មោះពេញឈ្មោះអីដែរ?

រ៉េម ៖ ឈ្មោះខ្ញុំនោះ លីម សារ៉េម ។

ដានី ៖ មីងសព្វថ្ងៃអាយុប៉ុន្មានហើយ?

រ៉េម ៖ ខ្ញុំ ៥៣ ។

ដានី ៖ មីងស្រុកកំណើតកើតមីងជានៅណា?

រ៉េម ៖ នៅនេះដើងវត្ត ។

ដានី ៖ ស្រុកកំណើតនៅដើងវត្ត?

រ៉េម ៖ ចាំៗ ។

ដានី ៖ ភូមិដើងវត្ត ឃុំអី?

រ៉េម ៖ ឃុំព្រះនេត្រព្រះ ។

ដានី ៖ ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ?

រ៉េម ៖ ចាំ!

ដានី ៖ ចឹងមីងសព្វថ្ងៃរស់នៅក្នុងភូមិឃុំដដែល?

រ៉េម ៖ ចាំៗ ។

ដានី ៖ គ្រួសារមីងឈ្មោះអី?

រ៉េម ៖ ងិន រួន ។

ដានី ៖ ប្ដីមីងគាត់ឈ្មោះ ងិន?

រ៉េម ៖ ចាំ! ងិន រួន ។

ដានី ៖ សព្វថ្ងៃពូអាយុប៉ុន្មាន?

រ៉េម ៖ ឪ ៥២ហើយ ប្អូនខ្ញុំម៉ាឆ្នាំ ។

ដានី ៖ មីងមានកូនចៅទាំងអស់ប៉ុន្មាននាក់?

រ៉េម ៖ កូន៥នាក់ ។

ដានី ៖ កូន៥នាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

រ៉េម ៖ ស្រី៤ ប្រុស១ ។

ដានី ៖ មីងសព្វថ្ងៃប្រកបមុខរបររកស៊ីធ្វើអីដែរ?

រ៉េម ៖ មានធ្វើអី រកត្រីប៉ុននោះឯង ។

ដានី ៖ រកតែត្រី អត់មានធ្វើស្រែចំការទេ?

រ៉េម ៖ ខ្ញុំអត់មានស្រែផង ។

ដានី ៖ ចុះឪពុកមីងគាត់ឈ្មោះអីទោ?

រ៉េម ៖ ពុកស្លាប់អស់ហើយ ។

ដានី ៖ គាត់ឈ្មោះអីទៅស្លាប់?

រ៉េម ៖ ឪពុកឈ្មោះ លីម តិ ។

ដានី ៖ គាត់ស្លាប់តាំងពីអង្កាល់មក?

រ៉េម ៖ ស្លាប់ប៉ុន្មានឆ្នាំឪ ភ្លេច សម័យនេះឯង ។

ប្ដី ៖ ៨១ ៨២ ។

ដានី ៖ ចុះម្ដាយមីង?

រ៉េម ៖ តេង ម៉ៅ ។

ដានី ៖ គាត់នៅរស់ទេ ហើយក៏ស្លាប់ហើយ?

រ៉េម ៖ ស្លាប់ទាំងអស់ ។

ដានី ៖ គាត់ស្លាប់ពីអង្កាល់ដែរ?

រ៉េម ៖ មុនពុកខ្ញុំ ។

ដានី ៖ ចុះបងប្អូនប៉ុន្មាននាក់មីង?

រ៉េម ៖ បងប្អូនខ្ញុំនោះ រាប់មិនអស់ទេ វាច្រើនពេក ។

ដានី ៖ ទាំងអស់ប៉ុន្មានទៅ?

រ៉េម ៖ នៅរស់ ចែរ៉ាវ, រ៉ុំ, វឿង, រាប់មិនអស់ទេ បងច្រើនណាស់ បើរាប់ទៅកំប៉េចដែរ ។

ដានី ៖ ចុះមីងកូនទីប៉ុន្មាន?

រ៉េម ៖ ខ្ញុំនោះ មើលលោកបង ចែវ៉ាវ, បងខ្ញុំ រ៉ុ, វឿង, ខ្ញុំ ទី៦ហើយ ។

ដានី ៖ ទី៥ ហើយទី៦?

រ៉េម ៖ ទី៥ ។

ដានី ៖ ចុះមីងកូនទី៥?

រ៉េម ៖ ហ្នឹងហើយកូនទី៥ ។

ដានី ៖ ចុះប្អូនមីងមានប៉ុន្មាននាក់ទៀត?

រ៉េម ៖ មាន ប្អូនខ្ញុំមួយមានទិតសារិន១ ប្រុស១, រ៉ា, បុប្ផា, ភាគ ៤ ។

ដានី ៖ ទាំងអស់៩នាក់?

រ៉េម ៖ ៩នាក់ ។

ដានី ៖ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

រ៉េម ៖ ប្រុស២ ស្រី៧ ។

ដានី ៖ ចុះមីងកូនទី៥ ។ ចុះមីងកាលនៅក្មេងៗបានរៀនសូត្រដែរអត់?

រ៉េម ៖ លោកគ្រូអើយ រៀននឹងឯង ប៉ុនរៀនមិនបានចប់ រៀនទៅដល់អាពតទៅមិនបានរៀនចប់ទេ ។

ដានី ៖ រៀនបានដល់ថ្នាក់ទីប៉ុន្មាន?

រ៉េម ៖ ដល់ថ្នាក់ទី១២យើងពីសង្គម ។

ដានី ៖ នៅសាលាណា?

រ៉េម ៖ ភ្លេចហើយលោកគ្រូ សាលាព្រះនេត្រពះយើង ដឹងសាលាអី ។

ដានី ៖ ចុះមីងឈប់រៀននៅឆ្នាំណា?

រ៉េម ៖ យួនឲ្យអាពតចូលនឹងដឹងឆ្នាំណា មិនដឹងដែរ ។

ដានី ៖ ចឹងកាលពីរដ្ឋប្រហារទម្លាក់លន់ នល់ មីងនៅរៀនដែរអត់?

រ៉េម ៖ នៅៗរៀន ។

ដានី ៖ ពេលរដ្ឋប្រហារទម្លាក់សម្ដេច?

រ៉េម ៖ ទម្លាក់សម្ដេចខ្ញុំមិនទាន់បានចូលទេ ។

ដានី ៖ អត់ទាន់បានចូលរៀន?

រ៉េម ៖ នោះឯង ។

ដានី ៖ ចឹងរៀនដល់ឆ្នាំ៧៥ ប៉ុល ពត ចូលនឹង?

រ៉េម ៖ ចាំ!

ដានី ៖ ចុះមីងដល់ពេលប៉ុលពត ចូលឆ្នាំ៧៥ហើយ យ៉ាងម៉េចទៀតទៅ គេឲ្យមីងធ្វើអី?

រ៉េម ៖ អាពតចូលទៅ ឲ្យខ្ញុំចូលកងនារីកងចល័ត ។

ដានី ៖ ចូលកងចល័ត កាលនឹងមីងចូលកងចល័តនៅចល័តណា គេហៅចល័តអីគេ?

រ៉េម ៖ ចល័តនោះ មិនចល័តពិតប្រាកដទេ ដូចជាគេត្រូវការទៅខាងណា ក៏គេហៅទៅដាក់ ប៉ុនខ្ញុំវា ច្រើន ព្រៃមាន់ណាណែ យើងចេះដាក់ទៅនៅតូចៗចេះហៅដាក់ទៅ លើកទំនប់ លើកភ្លឺ ស្រែទៅណា ។

ដានី ៖ កាលនឹងមីងអាយុប៉ុន្មាន ពេលដែលប៉ុលពតចូលឆ្នាំ៧៥?

រ៉េម ៖ ៧៥ អាយុ១៥-១៦ ។

ដានី ៖ កាលនោះចូលដំបូង យើងចូលចល័តនៅក្នុងភូមិ?

រ៉េម ៖ ក្នុងភូមិយើងចល័តទេ ប៉ុនចល័តទៅអត់ដែលនៅជាមួយម៉ែឪទេ ។ ពេញចូលខាងនារីហើយ គេដាក់ខាងនារីបណ្ដោយ ។

ដានី ៖ ចូលចល័តដំបូង គេឲ្យធ្វើការងារអីខ្លះទៅ?

រ៉េម ៖ គេឲ្យលើកទំនប់ លើកភ្លឺស្រែ ។

ដានី ៖ លើកទំនប់ លើកភ្លឺស្រែនៅណាទៅ?

រ៉េម ៖ ខាងនេះ ខាងភូមិយើងនេះ ខាងព្រៃមាន់ អាវាលយើងនេះ លើកខាងភ្លឺស្រែ ។

ដានី ៖ ភ្លឺស្រែនៅភូមិយើង នៅព្រៃមាន់?

រ៉េម ៖ ចាំ! នៅព្រៃមាន់ លើកប្រឡាយតាមផ្លូវនោះ ។

ដានី ៖ ពីណាគេធ្វើប្រធានកាលនោះ?

រ៉េម ៖ កាលនោះក្នុងភូមិយើងនេះឯង ប៉ុនមើលភ្លេចទៅប្រធាន បើខ្ញុំទៅខាងនោះប្រធានខាងស្រែះ ប្រធានខ្ញុំឈ្មោះខ្មៅ បើខាងត្រពាំងថ្ម ខាងកូនខ្វែង ។

ដានី ៖ ចុះមីងទៅលើកទំនប់ត្រពាំងថ្មឆ្នាំណា?

រ៉េម ៖ លោកគ្រូអើយកាលនោះ មិនដឹងឆ្នាំណាទេ វាមិនដឹងឆ្នាំ ។

ដានី ៖ ប៉ុលពតចូលឆ្នាំ៧៥ ដល់ពេលបានប៉ុន្មានឆ្នាំបានមីងទៅ?

រ៉េម ៖ លើករហូតឲ្យតែយួនចូលភ្លាមដើរចល័តរហូត អឺ!ទាល់តែយួនចូលបានខ្ញុំឈប់ ។

ដានី ៖ ប៉ុន្តែចាំមើល ប៉ុលពតចូលមកឆ្នាំ៧៥?

រ៉េម ៖ ចាំ!

ដានី ៖ បាយរួមឆ្នាំ៧៥?

រ៉េម ៖ ចា៎!

ដានី ៖ ចឹងមីងលើកទំនប់តាមភូមិ ដូចថាលើកទំនប់ភ្លឺស្រែតាមភូមិ តាមព្រៃមាន់បានប៉ុន្មានឆ្នាំ បាន គេបញ្ជូនមីងឲ្យទៅខាងត្រពាំងថ្មី?

រ៉េម ៖ ដូចជាលើកលើកបានម៉ាខែចេះ ភូមិយើងត្រឹមម៉ាខែចេះ យើងទៅទៀតហើយ ទៅខាងវាល ខាងនោះ ទៅខាងវាលរំចេក ៗ ប៉ុន្តែខ្ញុំដើរសព្វទៅខាងវាលរំចេកនោះ ទៅបានយូរគ្រាន់ គេ បោះឲ្យយើង២-៣-៤-៥ខែ ៗ អានោះលើកទំនប់ដែរ ខាងវាលរំចេកៗភ្នំស្រុក ៗ ដល់វា ផុតទៅដើរវាច្រើន ខ្ញុំមិនដឹងថាចំណាំបាន ៗ បើទំនប់កូនខ្វែង ខ្ញុំធ្វើការលើកទំនប់ កូនខ្វែង ត្រពាំងថ្ម អានោះលើករាប់ខែដែរ ផ្លាស់គ្រប់កន្លែងដែរ ៗ

ដានី ៖ កាលត្រពាំងថ្មនឹង មីងអត់ចាំទៅឆ្នាំណា?

រ៉េម ៖ អត់បានចាំទេលោកគ្រូ ដឹងឆ្នាំណាទេ បើសិនណាលោកគ្រូឯងដើរសម្ភាសន៍គេលើកក្រោយ បើសិនជាគេនេះ គេដឹងឆ្នាំខ្លះ ប៉ុន្តែខ្ញុំមិនដឹងទេ ខ្ញុំអត់ដឹងឆ្នាំ ៗ

ដានី ៖ ចុះមីងអត់ដឹងឆ្នាំ ប៉ុន្តែទៅកាលនោះទៅគ្នាច្រើន?

រ៉េម ៖ អូ! លោកគ្រូអឺយ មនុស្សរាប់ពាន់នាក់ណាលោកគ្រូ លោកគ្រូឯងកាលណោះគេហៅថា ប្រជាជនថ្មីណាលោកគ្រូ ប្រជាជនថ្មីទៅមកពីពេញ មកពីបាត់ដំបង រួចយើងមកដុំគ្នា ហើយចុះយើងទៅលើកទំនប់ទាំងយប់ទាំងថ្ងៃនោះគេហៅម៉ាតំបន់យើងនេះឯង តំបន់៥នេះ ៗ

ដានី ៖ ចឹងទៅលើកទំនប់ត្រពាំងថ្មហ្នឹង កាលហ្នឹងទៅទាំងអស់ កងចល័តនៅតាម ស្រុកតាមភូមិ?

រ៉េម ៖ ចា៎ៗ ទៅកងចល័តតាមស្រុកតាមភូមិ តាព្រៃតាមវាលណោះរាប់មិនអស់ទេ ហេតុតែ សំណាងវាមិនបានស្លាប់ទេខ្ញុំ ៗ

ដានី ៖ ចុះមីងគេឲ្យទៅលើកទំនប់ត្រពាំងថ្ម លើកនៅម្តុំណា?

រ៉េម ៖ វាចាំមិនបានណាលោកគ្រូ លោកគ្រូអឺយខ្ញុំចាំវាមិនបានមែន ប៉ុន្តែថាមិនដែលដើរចូលភូមិទេ ហើយនៅខាងណា អាភូមិយើងមិនខាងកើតភូមិនេះភូមិត្រពាំងថ្មខាងកើតៗអាង យើងនៅ លិចភូមិ ៗ

ដានី ៖ កាលនឹងយើងលើកទៅ គេគ្រប់គ្រប់ម៉េច គេគ្រប់គ្រងតាមដូចថាយើងមកពីខាងព្រះនេត្រ ព្រះយើងគេដាក់ម្តុំ មកពីកន្លែងនោះ គេដាក់ម្តុំ ឬក៏លើកចំរុះគ្នា?

រ៉ែម ៖ ចា៎! ចំរុះៗគ្នា បើគេរើកផ្សេង កផ្ស ។ ដូចជាពួកខ្ញុំចេះ បើខ្ញុំទៅខាងនេះភ្នំកូនខ្វែងចេះ នោះ ខ្ញុំកាន់កងតូច គេដាក់ឲ្យកាន់កងតូច កាលនោះគេបែកទឹកគ្នា ។

ដានី ៖ ចឹងលើកទំនប់ត្រពាំងថ្មមុនកូនខ្វែង១មុន?

រ៉ែម ៖ ត្រពាំងថ្មមុន បាននាំយើងចុះទៅកូនខ្វែង លើកបណ្ដើរគ្នា ។ ឯងនេះអាងត្រពាំងថ្មរួច យើងចុះទៅខាងនោះម្ដង ។

ដានី ៖ កន្លែងកូនខ្វែង អាងត្រពាំងថ្មជាប់គ្នាឬយ៉ាងម៉េច?

រ៉ែម ៖ ចុះៗទៅជើងត្រពាំងថ្ម ម្ខាងម្នាក់ ហើយទំនប់នោះខ្ពស់មហា ។

ដានី ៖ ទំនប់ណាខ្ពស់?

រ៉ែម ៖ ចា៎! ទំនប់អាងត្រពាំងថ្មក៏ខ្ពស់ ឯងនោះអាងកូនខ្វែងក៏ខ្ពស់ដែរ ។

ដានី ៖ កំពស់ណា?

រ៉ែម ៖ អូ! លោកគ្រូអើយនិយាយពីរែកៗហើយ យើងស៊ីបបរវាស់វែកទេ លោកគ្រូគិតមើល ហើយពួកនោះស៊ីអត់ដែលឆ្អែតទេ ខ្ញុំចូលព្រៃ ។ ហើយយើងដែលស្គាល់អានេះជើងគោ គេហៅជើងគោ ដូរៗកញ្ចុំ ពួកខ្ញុំស៊ីមិនដែលឆ្អែតទេ ពួកខ្ញុំចូលព្រៃបេះមកនាំគ្នាជ្រលក់ ប៉ុនមិនមានអំបិលស៊ីទេ ស៊ីតែទទេរ ធ្វើម៉េចឲ្យយើងបានរស់ ។ ហើយយប់ឡើងចេះ វាធ្វើវេងចេះ ហែលៗ យើងដេកម៉ាកង១ចេះ យប់ឡើងដឹងតែបាត់ហើយ វាយកយើងទៅវៃចោល ។

ដានី ៖ ម៉េចចឹងបានយកទៅវៃចោល?

រ៉ែម ៖ យើងខ្ជិលចេះ ឲ្យយើងឈឺចេះ យើងឈឺចេះយើងស្នើសុំគេសម្រាកហើយ ថាយើងខ្ជិល ហើយ យើងខ្ជិលចេះដឹងតែបាត់ខ្លួន ថាយើងពុត យើងឈឺសតិអារម្មណ៍ ។

ដានី ៖ ចុះកងរបស់មីង មានគេយកទៅវៃចោល?

រ៉ែម ៖ មាន ។

ដានី ៖ មីងចាំ ពីអ្នកណាខ្លះគេយកទៅវៃចោល?

រ៉ែម ៖ ចំរុះ ដូចមិនមានគ្នា គេអ្នកផ្សេងចេះ ខ្ញុំមិនសូវស្គាល់អត់មានភូមិតែមួយ លោកគ្រូដឹងតែបាត់ៗចេះ ហើយដូចគេស្នើចេះ អត់ទាន់បើកវគ្គ ដល់ចឹងទៅគេយកអាប្រុសទៅវៃចោល១ ខ្ញុំកាន់កងតូច ដូចអន្ទង់ខ្ញុំជីកស្នានេះ២ម៉ែត្រដែលវាវាស់ឲ្យ ហើយយើងលើកនោះលើកឲ្យ រួចក្នុងម៉ាថ្ងៃ២ម៉ែត្រគឺបណាជីវៅវាកន្លះម៉ែត្រ ដល់តែនេះទៅវាយកអានោះទៅវៃចោល ហើយខ្ញុំអត់ដែលបានទំនាក់ទំនងគ្នាទេ

ហៅអាប្រុសស្នើយើង មានគេស្នើយើង។ ស្នើមែន ប៉ុនអត់ដែលបាននិយាយគ្នាទេ ដល់គេយកទៅវៃចោលទៅព្រឹកឡើង ក៏ខ្ញុំមិនដឹងថាគេយកទៅ វៃចោល។ ខ្ញុំក៏នៅគ្នាខ្ញុំទៅ ហើយវាតាមដានខ្ញុំលើកអាងត្រពាំងថ្មឡើងចប់ អាងកូនខ្វែង ឡើងចប់ នៅតែក្រោយខ្ញុំទេ ខ្ញុំប្រាប់ អន្ទង់ខ្ញុំនៅត្រង់ណា វានៅត្រង់នោះឯង កងឈ្លបវា នោះ។ ហេតុតែសំណាងខ្ញុំអត់មានងាប់ វាតាមដានយើងខ្លាចយើងនិយាយនឹកឃើញ ស្រណោះអានេះដែលគេយកទៅវៃចោល ខ្ញុំមិនដែលនិយាយទេៗម៉្លេះហើយ បានខ្ញុំរួចខ្លួន ដល់ប៉ុននេះ។ បើសិនតែយើងនិយាយតែគ្នាយើងថា "ហ៎!អើយមើលនេះ គេយកវៃចោល ស្រណោះ" ខ្ញុំបាត់ខ្លួនយូរណាស់។ ខ្ញុំមិនដែលសោះ ខ្ញុំមិនដែលនិយាយរឿងអីទេ អ្នកណា យកវៃចោលណា យកទៅ។

ដានី : ពីណាគេដែលស្នើមីង ដែលគេយកទៅវៃចោល?

រ៉េម : ភូមិខ្ញុំនឹងឯង។

ដានី : ម៉េចបានគេយកទៅវៃចោល?

រ៉េម : ថាឯងប្រវត្តិទាហានៗពីដើម។

ដានី : ឈ្មោះអី?

រ៉េម : ឈ្មោះ ឆួយ។

ដានី : ឆួយ?

រ៉េម : ចា៎!

ដានី : ទៅលើកទំនប់ជាមួយ?

រ៉េម : ចា៎! លើកទំនប់។

ដានី : គេយកទៅឆ្នាំណា?

រ៉េម : លោកគ្រូថា ខ្ញុំវាមិនដឹងឆ្នាំ។

ដានី : ចឹងលើកនឹងគេឲ្យយើងលើកម៉ាថ្ងៃឲ្យអស់២ម៉ែត្រគីប?

រ៉េម : ចា៎! ក្នុងម៉ាថ្ងៃ២ម៉ែត្រគីប បើមិនរួចគេមិនឲ្យឡើង យប់ឡើង។

ដានី : បាននឹងថាទៅលើកនឹងគេមានបែងចែកកម្លាំងទី១ត្រូវលើកប៉ុន្មាន កម្លាំងទី២?

រ៉េម : ហ្នឹងឯងកម្លាំងទី១ពួកខ្ញុំនឹងឯង។

ដានី : កម្លាំងទី១ពួកមីង?

រ៉េម : ចា៎!

ដានី ៖ អានឹង២ម៉ែត្រគីប?

រ៉េម ៖ ចា៎!

ដានី ៖ ចុះកម្ពាំងទី២?

រ៉េម ៖ កម្ពាំងទី២នៅក្នុងភូមិ ។

ដានី ៖ ចុះលើក២ម៉ែត្រគីប ហើយលើកកន្លែងពីដីក ហើយនឹងកន្លែងគេចាក់?

រ៉េម ៖ ឡើងទៅទំនប់ចាក់នោះ ។

ដានី ៖ ឆ្ងាយទេ ម៉ាដើង១?

រ៉េម ៖ ឆ្ងាយគ្រាន់ ប្រហែលពីនេះទៅនោះ ម៉ាដើងទំនប់វាទៅដូចជាដូរចេះទៅ វាវាស់វាយគ្នាចេះ ២ម៉ែត្រគីបចេះ ។ យប់ឡើងធ្វើទៀត ។

ដានី ៖ ម៉ាថ្ងៃនឹងលើកហើយដែរ ២ម៉ែត្រ?

រ៉េម ៖ និយាយមិនរួច១ ។

ដានី ៖ រួច?

រ៉េម ៖ ចា៎!

ដានី ៖ ២ម៉ែត្រគីប?

រ៉េម ៖ ចា៎!

ដានី ៖ ចុះប្រុស១ប៉ុន្មានម៉ែត្រ?

រ៉េម ៖ ប្រុស១កងគេផ្សេង ។

ដានី ៖ ចុះមីងចាប់ផ្តើមលើកពីម៉ោងប៉ុន្មាន យើងព្រលឹមឡើងចេញម៉ោងប៉ុន្មាន?

រ៉េម ៖ ចា៎! ម៉ោង៦ទៅហើយ ម៉ោង៦ទៅចុះ ដែលកំណត់ម៉ោង៦ ។

ដានី ៖ មានហូបបបរពេលព្រឹកដែរ?

រ៉េម ៖ អត់១ចូលគ្នាបណ្តោយ ដល់ម៉ោង១២ ។

ដានី ៖ ម៉ោង១២?

រ៉េម ៖ ចា៎!

ដានី ៖ ហូបអ្វីគេ?

រ៉េម ៖ បបរ អត់ដែលមានបាយទេ ។

ដានី ៖ ហូបបបរអត់មានបាយ?

រ៉ែម : អត់ចែកគ្នាទៀត អត់មានយើងស៊ីម៉ាសេរី ចែកគ្នាបើថាម៉ាវែកសម្លយើងម្នាក់ម៉ាវែកស្មើ ហើយទឹកកាលខ្ញុំនៅលើកនោះ ទឹកចែកគ្នាម្នាក់ម៉ាកូនកា-កូនផ្តិលប៉ុននោះ ។ អ្នកណាឆ្អែតក៏ឆ្អែត អ្នកណាក៏មិនឆ្អែត តាមដំណើរ ឯនោះអត់ទឹក ។

ដានី : អត់មានទឹក?

រ៉ែម : អត់ កាលខ្ញុំលើកអត់មានទឹកទេ កណ្តាលព្រៃៗវាល ហើយឆ្នាំនោះអត់មានទឹកទៀត ។

ដានី : អត់មានភ្លៀង?

រ៉ែម : អត់ ក្រទឹកទៅ ក៏វាស់ទឹកចែកគ្នាបណ្តោយ ។ ហើយលោកគ្រូឯងគិតមើល ម៉ាកងធំអី! ម៉ាកងតូចខ្ញុំ៣០នាក់ ឆ្នាំងប៉ុននេះ ឆ្នាំងធំយើងវាស់ចែកគ្នា ស៊ីបបររួចវាស់ទឹកចែកគ្នាកំសត់ណាស់លោកគ្រូអើយ ។

ដានី : ចុះដល់ពេលម៉ោង១២ហូបបបរៗហើយ ម៉ោងប៉ុន្មានចុះ?

រ៉ែម : ចា៎! ហូបបររួចសម្រាក់ប្រហែលមិនបានកន្លះម៉ោងទេ កន្លះម៉ោងចុះៗទៀត ។

ដានី : ធ្វើដល់ម៉ោងប៉ុន្មានបានឈប់?

រ៉ែម : ធ្វើដល់ម៉ោង៥-៦ ប្រហែលម៉ោង៦ចុះ កាលជំនាន់នោះ ។

ដានី : ទាល់តែរួចបានឈប់ចឹង?

រ៉ែម : ចា៎!

ដានី : អ្នករួចមុនឈប់មុន អ្នករួចក្រោយ ឈប់ក្រោយ អត់ឈប់ស្មើគ្នា?

រ៉ែម : ចា៎! ឈប់ស្មើតែគ្នា ធ្វើ ។

ដានី : ជួយគ្នាដែលអត់ យើងជួយគ្នា?

រ៉ែម : ចា៎! កងតូចយើងរួចចេះ បានឡើង ។

ដានី : ចុះឧបមាថាខាងក្នុងនឹង អ្នកខ្លះវែករួច អ្នកខ្លះវែកអត់រួចចឹងយើងជួយគ្នា?

រ៉ែម : អត់ហ៊ាន.....គ្មានអីបើខ្ញុំចេះទៅតែខ្ញុំធ្វើម៉េចឲ្យទៅរួច ។ ចុះឡើងមើលឡើងងើយចេះ យើងវែកឡើងទៅ ។ ហើយយប់ឡើង ឲ្យធ្វើការទៀត មិនមែនធ្វើការតែថ្ងៃទេណា ។

ដានី : ធ្វើអីទៀត?

រ៉ែម : យប់វែកដីដែរ ប៉ុនវាអត់វាស់កំណត់ឲ្យទេយប់នោះ វាដេញយើងធ្វើទៅ ។ ប៉ះត្រង់ណាក៏គ្នាបានទៅឈឺអីចឹង យកទៅវៃចោល ។ តែឈឺ តែលោកគ្រូថាមិនទៅតែ២-៣ថ្ងៃ ដឹងថាបាត់ ខ្លួនហើយ ជាពិសេសប្រជាជនថ្មី ។

ដានី : ពីណាយកទៅវៃចោល?

រ៉េម ៖ អង្គការនឹងឯង ។

ដានី ៖ អង្គការនោះអ្នកណាគេ?

រ៉េម ៖ អង្គការនោះប្រធានយើងនោះឯង ប្រធានដែលគ្រប់គ្រងយើង ប៉ុន......(ស្ដាប់មិនបាន) មិនហ៊ានមើលមុខគេ ។

ដានី ៖ ពូឈ្មោះគាត់?

រ៉េម ៖ ខ្ញុំមិនដែលហ៊ានមើលមុខគេផង ។

ដានី ៖ អត់ដែលស្គាល់ ចុះអ្នកគ្រប់គ្រងនៅទំនប់ឈ្មោះអី?

រ៉េម ៖ ភ្លេចហើយលោកគ្រូអើយ ភ្លេចអ្នកគ្រប់គ្រងបាត់ទៅ អ្នកគ្រប់គ្រងនេះមិនស្រុកភូមិយើង ពួកនិរតី ។

ដានី ៖ មកពីណា ឈ្មោះអី?

រ៉េម ៖ និរតីនោះ ប៉ុនពួកបងយ៉ាន ពួកអីនេះ គាត់នៅក្នុងភូមិទេ គេគ្រាប់ដេញបញ្ជូនឲ្យយើងទៅនោះអង្គការនោះផ្សេងទៀត ប៉ុនខ្ញុំមិនបានយកចិត្តទុកដាក់ កាលនោះខ្លាចផង មិនបានទៅស្គាល់ឈ្មោះទេ ។ ចាំមិនបានទេលោកគ្រូអើយ ដល់ខ្ញុំចាស់ទៅកាន់ភ្លេចភ្លាំងផង វាភ្លេចអាឈ្មោះមិនបានយកចិត្តទុកដាក់ទៀត អាឈ្មោះអាពត ។ ផ្អែតហើយខ្ញុំបានរស់ដល់ប៉ុននេះ ។

ដានី ៖ ចឹងមីងលើកនៅនឹងរយៈពេលប៉ុន្មានខែ?

រ៉េម ៖ ខ្ញុំលើកឯនោះ យូរ បែបដាងផា៣ខែទៅចុះ ខ្ញុំបាន៣ខែត្រឹមរួចទៅខ្ញុំចល័តទៅទៀត គ្រាន់កន្លះខែ ម៉ាខែ ខ្ញុំបកមកភូមិវិញ ។ ខ្ញុំនោះទៅ៣ខែ ចង់ពាយ ចាញ់ក៏ចាញ់ដែរកាលនោះ ។

ដានី ៖ កូនខ្វែង?

រ៉េម ៖ ចា៎!

ដានី ៖ ចាញ់ខ្លាំង?

រ៉េម ៖ ចាញ់ ។

ដានី ៖ ចុះមីងចាញ់ដែរ?

រ៉េម ៖ ខ្ញុំចាញ់តើ ខ្ញុំចាញ់ៗបានថ្នាំហើយគេអ្នកស្គាល់គ្នាចេះធ្វើការជាមួយគេអង្គការធំទៅក៏បានសុំថ្នាំមកឲ្យលេប បានខ្ញុំជា បានលើកទំនប់បាន ។

ប្ដី ៖ បានថ្នាំសូន្យដូចអាចម៍ទន្សាយ ។

ដានី ៖ ដូចអាចម៍ទន្សាយ លេបទៅជាដែរ?

រ៉េម ៖ ចេះតែជាទៅណា ។

ដានី ៖ បានមកលេងផ្ទះទេកាលនឹង?

រ៉េម ៖ ទាល់តែអង្គការធ្វើនោះរួច អង្គការឲ្យមកបានជួបម្ដាយៗបានប៉ុន្មានខែ បានប៉ុន្មានថ្ងៃក៏ទៅទៀត ។ ប៉ុនយើងមកនៅក្នុងភូមិនេះក៏មិនបានសុខ គេប្រើយើងដក ខែដកសំណាបយើងទៅ ខែច្រូតក៏យើងទៅ យើងមិនដែលបាននៅទេ ។ ដែលបាននៅផ្ទះ បើយើងនៅផ្ទះវិញ យើងមិនដែលបាននៅទេ ចេះតែឲ្យយើងធ្វើនេះធ្វើនោះវាស់ល្ងាច ។

ដានី ៖ ចុះមីងកាលដែលយើងនៅអាងត្រពាំងថ្មនឹង យើងចំរុះគ្នាជាមួយប្រជាជនចាស់ ជាមួយប្រជាជនថ្មីលើកជាមួយគ្នាដែរ?

រ៉េម ៖ ចា៎! ចំរុះគ្នា ។ ខ្ញុំស្រណោះប្រជាជនថ្មី ។

ដានី ៖ ចុះអ្នកគ្រប់គ្រងមកពីនិរតី?

រ៉េម ៖ ចា៎! និរតី ។

ដានី ៖ ពីណាគេ និរតី?

រ៉េម ៖ និរតី នែក! ស្រីៗ ។

ដានី ៖ ស្រី?

រ៉េម ៖ ចា៎! សុទ្ធតែស្រី ពួកខ្ញុំខាងខ្ញុំសុទ្ធតែស្រី ។ បើយោធាៗមែនៗយោធាខាងនោះមានដែរ គេមកមានយោធាមាននិរតី ប៉ុនគេមិនមែនកំប៉េចកំប៉ុកនឹងយើងប្រជាជន ។ យើងប្រជាជនក៏មិនដែលទៅហ៊ាន ។

ដានី ៖ មានដែលប្រជុំជាមួយគេ?

រ៉េម ៖ ប្រជុំរហូត ។

ដានី ៖ ប្រជុំជាមួយពីណាគេ?

រ៉េម ៖ ប្រជុំប្រធានធំដូចជាកាន់ធំចឹងទៅ គេសុទ្ធតែអង្គការៗដូចជានេះឯងគេមកប្រជុំទៅ ។

ដានី ៖ យាយចែម ដែលឮឈ្មោះយាយចែម?

រ៉េម ៖ យាយចែម ។

ដានី ៖ មីងធ្លាប់គាត់ដែរ?

រ៉េម ៖ ឮ ។

ដានី ៖ គាត់មកប្រជុំពួកមីងនៅត្រពាំងថ្មដែរ អត់ទេ?

រ៉េម ៖ យាយចែម ។ ទេ! មិនដែលមកទេ ។

ដានី ៖ មីងដែលឃើញមុខយាយចែម?

វើម ៖ អត់ ខ្ញុំមិនដែលសូវឃើញ ឮតែឈ្មោះ ។

ដានី ៖ ឮថាគាត់ធ្វើអីទៅ?

វើម ៖ គាត់ធ្វើអី ធ្វើខាងយោធា ខាងកាន់ ។

ប្ដី ៖ ស្ដីទេ យាយចែមៗ កាចណាស់ ។

ដានី ៖ យាយចែមកាច?

វើម ៖ កាច យាយនោះឯងមានកណ្ដាញ់ៗ ។

ដានី ៖ យាយណា?

វើម ៖ យាយចែម គាត់មានកំណ្ដាញ់ គេថាខ្លាំងណាស់ ។

ដានី ៖ ខ្លាំងម៉េចទៅ?

វើម ៖ ខ្លាំងវៃអត់មានខ្លាច ។

ដានី ៖ វៃគេចោល កាច? ស្គាល់តាវ៉ាល់?

វើម ៖ តាវ៉ាល់នឹង មាឌវៀងស្ដើងខ្ពស់ បើយើងយូរៗឃើញម្ដង ស្ដើងខ្ពស់ ។

ប្ដី ៖ តាវ៉ាល់នឹង ត្រពាំងថ្មអី តាវ៉ាល់ ។

ដានី ៖ លើកត្រពាំងថ្ម ឈ្មោះតាវ៉ាល់?

វើម ៖ ចា៎! តាវ៉ាល់ គេហៅទំនប់តាវ៉ាល់ៗត្រង់ណា ខាងលិចស្រែះទំនប់តាវ៉ាល់ ។

ដានី ៖ ចុះតាវ៉ាល់នឹង គាត់យ៉ាងម៉េចទៅ?

វើម ៖ មេគេ ប្រធានតំបន់ ។

ដានី ៖ គាត់នៅរហូតដែរ ឬយ៉ាងម៉េច?

វើម ៖ ទេ! មិនដែលឃើញ ក៏យួនចូល មិននេះទេណា ដូចជាពាយ័ព្យនៅកាន់ចេះ កាន់មុនៗ ដល់និរតីចូលមកកំចាត់ពាយ័ព្យចោលអស់ យកពាយ័ព្យវៃចោលអស់ ។ វៃចោលនោះដឹងថាភូមិនេះដូចជាគាត់តានេះគាត់អ្នកកាន់ តាហ៊ិន គាត់អ្នកកាន់ក្នុងភូមិ ។ ដល់និរតីចូលមកពេកតាហ៊ិនបាត់ វៃចោលអស់រលីង ។ ហើយបញ្ចប់នេះ បញ្ចប់និរតីនៅនឹង ពាយ័ព្យបាត់អស់ហើយ យកទៅវៃចោលអស់អត់មាននៅសល់ទេ ទាំងប្រុសទាំងស្រី ។

ដានី ៖ យាយចែមពីណា?

វើម ៖ យាយចែមដឹងខេត្តណាទេ ឮតែឈ្មោះ អត់មាននៅខេត្តយើងទេ ។

ដានី ៖ ប៉ុន្តែគាត់មកពីភូមិភាគណា?

*រ៉េម :* ដឹងថាមកពីកើតនោះឯង ។

*ដានី :* យាយថែមនឹង គាត់អ្នកពាយ័ព្យ ឬអ្នកនិរតី?

*រ៉េម :* យាយថែមនិរតីៗ ។

*ដានី :* យាយថែមនិរតី?

*រ៉េម :* ចា៎!

*ដានី :* គាត់ធ្វើធំដែរ យាយថែម?

*រ៉េម :* ធំ ប៉ុន្តមិនបានកាន់ខ្ញុំទេ គាត់កាន់តំបន់នោះៗ ។

*ដានី :* ខាងណា?

*រ៉េម :* ទៅកើត តំបន់គាត់ ។ មើលតំបន់៥ តំបន់៣ ។ ហើយពួកខ្ញុំនេះនៅតំបន់៥ ហើយពួកខាងនោះស៊ីងនៅតំបន់៣ ។

*ដានី :* ខាងណា?

*រ៉េម :* ខាងនោះស៊ីង ខាងត្បូងដូនឡឹកនោះតំបន់៣ ហើយខាងខ្ញុំនោះទៅតំបន់៥ ទៅខាងណានោះតំបន់ប៉ុន្មានទៀត កាលនោះដើរ ។

*ប្តី :* ផាប់ដាងគេមានតំបន់៥ តំបន់៣អត់សូវទេ ។

*រ៉េម :* ហើយនឹងអត់ៗតំបន់៥ដាងគេ ប្អូនខ្ញុំទៅនេះ ទៅបូតស្រូវវាចាប់ចង យើងបូតស្រូវ ហើយយើងធ្វើការកម្លាំងយើងលើកកម្លាំងយើង វាវៃចោលដែរ ។ ហើយប្អូនខ្ញុំទៅនេះទៅបូតស្រូវ វាលបានដែលប៉ុននេះមក វាចាប់យកមកដាក់ស្រែះ វាចាប់ចងម៉ាយប់ វាថានឹងវៃចោល យប់នេះឯង ប៉ុនហេតុសំណាងវារត់មករួច ។ កាលនោះយើងភិតភ័យៗ ដឹងថាយប់ថ្ងៃនេះ យើងរស់ហើយ ស្អែកយើងស្លាប់ៗ គិតតែប៉ុននោះឯង អត់មានគិតពេលរស់ទៅទៀតទេ ។ ព្រោះក្នុងម៉ាផ្ទះ យើងយប់ឡើងនេះ បើថាម៉ាជុំវិញផ្ទះ សុទ្ធតែស្បែកជើងបូព៌ា ព្រឹកឡើង ក្រោកមើលសុទ្ធតែស្បែកជើងបូព៌ា ។ ហើយវាតាមដានយើង ឈ្លបមើលយើង ក្រែងយើង និយាយ ។

*ដានី :* ស្បែកជើងបូព៌ាម៉េច?

*រ៉េម :* ស្បែកជើងវាមកឈ្លបតាមផ្ទះយើង អាកង់ឡានយើងវាមានស្នាម ស្បែកជើងបូព៌ា ស្បែកជើងកង់ឡាន ។

*ដានី :* ម៉េចបានហៅស្បែកជើងបូព៌ា?

*រ៉េម :* ចុះកាលខ្ញុំហៅស្បែកជើងបូព៌ា កាលសម័យអាពត ហៅតែចឹង ។

ដានី : ហៅស្បែកជើងបូញ៉ា?

រ៉េម : ចា៎!

ដានី : ស្បែកជើងកង់ឡានហៅស្បែកជើងបូញ៉ា?

រ៉េម : ចា៎! ស្បែកជើងបូញ៉ា ។

ដានី : ចុះម៉េចបានហៅស្បែកជើងបូញ៉ាចឹង?

រ៉េម : ចុះបើទម្លាក់វាឲ្យហៅស្បែកជើងបូញ៉ាចុះឯង វាបើកឲ្យ បើស្បែកជើងនោះ ស្បែកជើងកង់ឡានទេវាធ្វើកង់ឡាន ។ ប៉ុនវាមានស្នាមជើងវាជីងដើរជីត្រង់ណា ដឹងថាមានស្នាមត្រង់នឹងស្បែកជើងនឹង ។ ហើយយប់ឡើងចេះ យើងដេកកុំឲ្យយើងនិយាយ តែយើងនិយាយដឹងថាមានបាត់ខ្លួនហើយ ។ ហើយថាឲ្យយើងត្រូវដាំដើមកពីមុខផ្ទះៗបានយើងរស់ គេស៊ើបប្រវត្តិយើងទាហាន ឬមួយប្រវត្តិយើងពីមានពីជំនាន់មុន ពីសង្គម អានោះដឹងថាយើងសាប់ហើយអត់បានសល់ទេ សាប់ទាំងអស់ បងថ្លៃខ្ញុំអីសាប់អស់ គេយកទៅវៃចោល មិនមានសល់ទេ ។

ដានី : ចឹងមីងលើកទំនប់ត្រពាំងថ្មនឹងចប់ គេឲ្យទៅលើកទំនប់កូនខ្វែង?

រ៉េម : ចា៎! កូនខ្វែងៗចប់បានយើងឡើងមកសម្រាកនៅផ្ទះ៤-៥ថ្ងៃ យើងទៅវាដាក់ទិសមកពីលើថាឲ្យយើងទៅលើកទំនប់ឯរំចេក ដូចជាអង្គការគេមកថាយើងត្រូវតែទៅទាំងយប់ៗ ទៅថ្ងៃយើងទៅថ្ងៃ អត់មាននេះគេចផុតបានទេ ។

ដានី : តែមីងអត់ចាំថាទៅត្រពាំងថ្មនឹងបានប៉ុន្មានខែឲ្យច្បាស់លាស់ទេ?

រ៉េម : លោកគ្រូអើយ ភ្លេចហើយ បើសួរទៅចុះខ្ញុំទាល់ បើសិនវាយូរណាស់ទៅបើសិនណាអ្នកគេ អ្នកចាំ គេចាំបាន បើខ្ញុំចាំមិនបានទេ ។ ដូចខ្ញុំវាឈឺផងអីផង សព្វថ្ងៃគិតច្រើនទៅផងអី ច្រើនមិនដឹងយ៉ាងម៉េច បើយើងជំនាន់ដែលយើងមិនទាន់មានពីដើមៗឲ្យចេះចាំបាន ដល់ ចាស់យូរទៅ វាយាប់ ។

ប្ដី : នាងឯងគិតមើលថាឈ្លបថាកំពស់ៗប៉ុននេះ មនុស្សចាស់ប៉ុនណាណៃគ្មានកម្លាំងនឹងតប់វាៗចាប់យកទៅវៃចោល គ្មានកម្លាំងអីតទៅរួច ។

ដានី : ចុះខាងកាលនឹងពីណាគេអ្នកបញ្ជាឲ្យយកទៅវៃចោលវៃអី?

រ៉េម : មានថាអង្គការៗនឹងមិនដែលស្គាល់អង្គការណាផង ស្គាល់តែអង្គការយោធាដែលគេមកប្រជុំយើងម្ដងៗ ។

ដានី : អ្នកខស្សាហ៍មកប្រជុំ មីងស្គាល់ឈ្មោះ?

រ៉ែម ៈ ប្រជុំមានតែយោធាៗ មានតែអាពតនោះឯងដូចមិនមែនយើងនេះទេ ដូចមកពីណាពីណែគេឲ្យមកកាន់ក្តាប់ លោកគ្រូអើយយោធាគេនោះវាសាហាវមែនឯង មើលគួរតែខ្លាចៗ មកបន្ទាប់គេខ្លាចកាំភ្លើងគេប្រដេប្រដាគួរតែខ្លាចណាស់លោកគ្រូ ។
យើងមិនដែលស្គាល់ឈ្មោះ វាទេ ។

ប្តី ៈ ចុះមកកូនឡានគេ ប្រជុំរួចក៏គេទៅបាត់ ។

រ៉ែម ៈ អូ! ជំនាន់អាពតនិយាយឡើងនាំឲ្យឈឺចាប់ទេ ។

ដានី ៈ ចុះហូបបបរហូត អត់មានបានបាយហូប?

រ៉ែម ៈ អត់មានបានបាយទេ បើសិនយើងនៅ បើយើងធ្វើការនៅកន្លែងលើកទំនប់លើកអី មានបបរអីខាប់ៗវាស់ចែកគ្នាម្នាក់ម៉ាវែកអីទៅ យើងធ្វើការទៅ ពួកទឹកប្រហុកវាវឃ្លោកទៅណាចែកគ្នា ចែករបបគ្នា ទឹកប្រហុកកន្លះវែកៗ ក៏យើងស៊ីទៅ ។ ស្មានណាបើខ្ញុំលើកទំនប់កូនខ្លែង វាចែកទឹកប្រហុកខ្ញុំ ចែករបបយើងម្នាក់ម៉ាវែក ហើយចែកទឹកប្រហុកយើងវាវទៅ ហើយយើងចូលទៅក្នុងព្រៃបេះដូចជាត្រួយស្ដៅ យើងយកមកគ្រាន់តែរោលភ្លើងកន្លែងចុងកៅវាទៅ យកមកស៊ីទៅ បានម៉ាចំអែត ម៉ាពេលហើយវាមិនឆ្អែតទៀត ។ ធ្វើការរឿងស៊ីបាយ ស៊ីបបរ ។

ដានី ៈ ចុះយើង....(ស្ដាប់មិនបាន) ?

រ៉ែម ៈ អានោះពេលដែលយើងសម្រាក យើងឡើងមកៗស៊ីបាយចេះណា ចែករបបចេះទៅ វាវៃជួនចែករបបទៅ យើងយកបាយមកទុកសិន និងទឹកប្រហុកទុកសិន ចុះនៅនឹងបៀតគៀនព្រៃ ។ ចូលទៅបេះមករោលទៅស៊ីទៅ ជ្រលក់ជាមួយទឹកប្រហុក ។

ដានី ៈ បាយពេលព្រឹក ហើយពេលល្ងាច ដឹងទេ?

រ៉ែម ៈ ពេលថ្ងៃ និងល្ងាច ។

ដានី ៈ ពេលថ្ងៃ និងល្ងាច?

រ៉ែម ៈ ចា៎!

ដានី ៈ យើងឆ្លៀតចូលព្រៃប៉េះមកម៉ាពេលហូបជាមួយបាយ?

រ៉ែម ៈ ចា៎! ប៉ុននោះឯង ហើយយើងយកទុកដាក់ក៏មិនបាន ។

ដានី ៈ អត់ដែលមានមាន់ សាច់ជ្រូកត្រីអីហូប?

រ៉ែម ៈ ទេ! ប៉ុននោះប្រសើរហើយ ត្រីមិនដែលស្គាល់ជាតិទេ មិនដែលទេ ឃើញទឹកប្រហុក ។

ដានី ៈ ចុះដែលឃើញមាន់អីដែរ?

រ៉េម ៖ អត់ មិនដែលទេ ពួកខ្ញុំមិនដែលស្គាល់ជាតិមាន់ទេ ។

ដានី ៖ ប៉ុនដែលឃើញគេចិញ្ចឹមមាន់?

រ៉េម ៖ អាកន្លែងគេ ពួកគេចិញ្ចឹមមាន់សុទ្ធតែមានគេចាត់ឲ្យយើងចិញ្ចឹមម៉ាដុប ពួកយើងខាងនេះការ ងារយើងនេះ អត់មានបៀតបនផង ។ ចល័តពួកខ្ញុំដើរចល័ត តាមវាលតាមដុប តាមព្រៃ ។

ដានី ៖ ចុះគេចិញ្ចឹមមាន់ ចិញ្ចឹមធ្វើអី បើគេអត់ឲ្យ?

រ៉េម ៖ ចិញ្ចឹមមាន់ ចាត់ទុកឲ្យពួកវានោះឯងស៊ី ។

ដានី ៖ ចឹង?

រ៉េម ៖ ចា៎! ដែលឲ្យយើងស៊ី ពួកវានឹងឯង ពួកអង្គការវានោះឯង ពេលវាចុះ ។

ដានី ៖ អង្គការមួយណា?

រ៉េម ៖ អង្គការដូចយោធា ប្រធានយោធានិរតី ដូចជាផ្ទះភូមិយើងចេះ មានផ្ទះវាផ្ទះនិរតីផ្ទះប្រធាន វា ទៅវាស៊ីម៉ាសេរី ពួកយើងហ៊ាន ស្រេចវាវៃដួងម៉ឺង១ក៏ទឹកបបរវាវឃ្លោក ។

ដានី ៖ ពួកអង្គការគេ១ហូបអីឆ្ងាញ់?

រ៉េម ៖ ចា៎! បាយវា បាយម្សៅស៊ីបវាអីមានស្រេច ហើយដល់យើងប្រជាជនអត់មានទេ តែ អំបិល វាមិនឲ្យយើងផងអត់ឲ្យយើងនៅផ្ទះទេ អំបិល មិនចែកអំបិលយើងទេ តែបានមួយ មិនមាន ។ យើងទៅចុះ បើយើងដើរចល័តចុះ មានតែបានមួយ ស្លាបព្រាមួយ ដែលវា ចែកយើង តែប៉ុននោះឯង ។

ដានី ៖ សាច់គោ ហេតុអីមិនដែលបានហូប ជំនាន់នឹង?

រ៉េម ៖ អត់ដែរទេ ។

ដានី ៖ ជ្រូកអី?

រ៉េម ៖ អត់ទេ ។

ដានី ៖ បានហូបតែទឹកប្រហុក?

រ៉េម ៖ ប្រហុក ។

ដានី ៖ ត្រី?

រ៉េម ៖ បើមានត្រីចេះ ក៏បើយើងទៅកន្លែងមានត្រីចេះ វាស្ងួត្រីឲ្យយើង យើងដាក់បន្លែទៅទឹកវាវ ឃ្លោកឲ្យយើងណា មិនមែនឲ្យយើងស៊ី មិនថានិយាយទេ វាទឹកម៉ាឆ្នាំងធំចេះ ម៉ាកងធំចេះ ទៅក៏ម៉ាខ្ទះត្នោតចឹងទៅ ទឹកឡើងវាវឃ្លោក ។

ដានី ៖ ពេលដែលមីងហូបបាយម្តង១ មើលទៅមានអារម្មណ៍ថាហូបបានឆ្អែតប៉ុនណា?

រ៉ែម ៖ មិនឆ្អែតទេលោកគ្រូ យើងចេះតែមួងកន្ទះពោះ យើងធ្លាប់ហើយធ្វើម៉េច ធ្លាប់ ។

ដានី ៖ ប៉ុន្តែយើងមានកម្លាំងរែកដី?

រ៉ែម ៖ ទៅទាំងចុះហើយ ទៅចុះមានកម្លាំង ប៉ុនយើងមានសាច់ ប៉ុនយើងទៅមានសាច់មានឈាមអីដូចគេ មានល្ងឹតល្ងៃចេះខំទៅ ។ ចុះធ្វើម៉េចបើវាមិនឲ្យនៅសុខ លោកគ្រូឯង ចុះបើនៅឈឺណា គ្រូនញាក់ញ័រយ៉ាងណា ក៏នៅមិនបានដែរ ទាល់យើងងាប់ព្រោងនៅនឹងកន្លែង បានវាសុខចិត្ត ។

ដានី ៖ ចុះមានអ្នកស្លាប់?

រ៉ែម ៖ មាន ស្លាប់អូរវ៉ៃចោល ។

ដានី ៖ ស្លាប់នៅកន្លែង ស្លាប់បណ្តោយ?

រ៉ែម ៖ ស្លាប់ក៏បាត់ជ្រាប១ កប់ចោលបាត់ជ្រាប ។

ដានី ៖ គេយកទៅកប់ណាទៅ បើស្លាប់?

រ៉ែម ៖ បើស្លាប់នៅព្រៃមានដៃ យកក្រវ៉ែងចោលក្នុងដុប ។

ដានី ៖ ដៃម៉េច?

រ៉ែម ៖ ដៃ១ យើងតាមដុប ព្រៃជ្រៅ១ ចេះក៏គេយកយើងទៅកប់តែម្តងទៅ ប៉ះត្រង់ណាក៏មិនពិបាកជីកដង ក្រវាត់ចោលយើងទៅ ។

ដានី ៖ ចុះនៅនឹងមានគុកមានអី ពេលលើកដីនៅត្រពាំងថ្ម?

រ៉ែម ៖ អត់មានគុកទេ ។

ដានី ៖ ចុះគេចាប់ គេយកទៅមីងថាបាត់ គេចាប់យកទៅណាទៅ?

រ៉ែម ៖ តែគេចាប់បាត់ហើយ ដឹងថាសូន្យ ។

ដានី ៖ ដឹងគេយកទៅណា?

រ៉ែម ៖ ដឹងគេយកវ៉ៃចោល ដឹងតែពេលប៉ុននោះ ។

ដានី ៖ គេវ៉ៃចោលណា?

រ៉ែម ៖ បើដឹងថាគេវ៉ៃចោល ដឹងគេវ៉ៃចោលឯងណា ដឹងថាបាត់រូប បាត់អីសូន្យបណ្តោយ ដឹងហើយមិនឲ្យយើងនិយាយទៀត ។

ដានី ៖ អត់ឲ្យយើងនិយាយសួរនាំទេ?

រ៉ែម ៖ អត់ទេ អត់ឲ្យយើងនិយាយទេ តែយើងនិយាយថាចេះចុះអីខ្សឹបគ្នាក៏មិនបាន អត់បានទេ វាយកទៅវ៉ៃចោលត្រង់ណាក៏ស្លាប់ទៅ អ្នកណាយកទៅវ៉ៃ ដូចជាខ្ញុំដេកសុខ១ចឹង គេយកខ្ញុំ

ទៅវ៉ៃចោលក៏ស្ងាត់ជ្រាបទៅ គ្នាយើងក៏មិនហ៊ាននិយាយថាយកមីនេះមីនោះទៅវ៉ៃចោលអត់ទេ ។

ដានី : បងប្អូនមីងគេយកមីងទៅទំនប់អាងត្រពាំងថ្មតែមីងមួយទេ?

រ៉េម : ចា៎!

ដានី : បងប្អូនអត់មានអ្នកទៅ?

រ៉េម : ចា៎! អត់មានអ្នកទៅ ពួកប្អូនខ្ញុំនៅតូចៗខាងកុមារៗនៅក្នុងភូមិគេដើរកាប់កន្ទ្រានខែត្រ កាប់អីធ្វើជី ។

ដានី : ចុះបងៗមីង?

រ៉េម : បងខ្ញុំគេមានប្តី មានប្រពន្ធអស់ទៅ ខាងកម្លាំងទី២ៗវ៉ៃយកណ្តាលនៅក្នុងភូមិ ហើយដកសំណាប ហើយយើងដាំដំឡូង ដាំពោតអីទៅណា ។

ដានី : ចុះមីងទៅនៅលើកទំនប់នឹង ភាគច្រើនស្រីៗ ប្រុសៗអត់ទៅ?

រ៉េម : ប្រុសមាន ប្រុសក៏ទៅ ស្រីៗក៏ទៅ ប៉ុនប្រុសតាមកងគេប្រុស អត់ឲ្យវាលាយវេក(ច្របូកច្របល់ទេ ខាងគេប្រុសទៅ ខាងខ្ញុំស្រីៗទៅ ។ បើវាស់ម៉ែត្រគឺបចេះដូចគ្នា បើវាស់ម៉ែត្រគឺបខាងគេប្រុសតាមប្រុសគ្នាគេ បើខ្ញុំស្រីម៉ាដួរខាងស្រីគ្នាខ្ញុំ អត់ឲ្យវាស់វេកទេ ។ លោកគ្រូឯងទៅខុសសីលធម៌វាវ៉ៃចោល អត់ដែលមានពេលរស់ ។ ដឹងថាលោកគ្រូឯងស្រឡាញ់ខ្ញុំឧទាហរណ៍ដឹងថាយប់ឡើងបាត់ហើយ បាត់សូន្យហើយ គ្មានពេលរស់ទេលោកគ្រូអើយ ។ នេះ ខុសសីលធម៌នៅមុខវត្តនេះ ប្រជុំ អង្គការគេមកប្រជុំមានអីគេចង ទាំងប្រុសទាំងស្រីសម្លាប់នៅកន្លែងឲ្យយើងឃើញនៅៗ ។

ដានី : នៅនឹងវត្តនឹង?

រ៉េម : ចា៎!

ដានី : អង្គការមកពីខាងណា?

រ៉េម : អង្គការធំគេ មកពីណាពីតំបន់ណា គេមកពីណាពីណោ គេនៅត្រង់ណាគេក្តោបក្តាប់ គេនៅតែនេះហើយ ទាល់តែគេប្រជុំបានឃើញគេមក គេវ៉ៃឲ្យឃើញតែម្តង អានោះខុសសីលធម៌កុំឲ្យយើងយកតាម វ៉ៃឲ្យឃើញសម្លាប់ចោលប្រួស អត់ហ៊ានមើលទេលោកគ្រូអើយ ។

ដានី : អត់ហ៊ានមើល?

រ៉េម : អត់ហ៊ានមើល ។

ដានី : ចុះមីងដែលធ្វើអីខុស គេព្រមានគេស្តីឲ្យ គេទិតៀនអត់?

រ៉ែម ៖ មានៗដែលយើងថា យើងឈឺចេះក៏ឈប់ម៉ាថ្ងៃ គេមកគេថាយើងហើយ គេកសាងយើងឲ្យយើងឈឺសតិអារម្មណ៍ត្រង់ណា សមមិត្តឯងឈឺមូលហេតុអ្វីៗ សមមិត្តឯងឈឺយ៉ាងម៉េចឈឺសតិអារម្មណ៍ស្អែកឡើងសមមិត្តឯងទៅ ។ ស្អែកឡើងដឹងថាយើងទៅហើយ ទៅទាំងឈឺហើយ ទោះបីយើងមិនជា ។

ដានី ៖ ពីណាអ្នកថាចឹង?

រ៉ែម ៖ និរតី ។

ដានី ៖ ស្គាល់ឈ្មោះ?

រ៉ែម ៖ ស្គាល់ក្នុងភូមិខ្ញុំស្គាល់ ដល់យើងចេញទៅ ។

ដានី ៖ ឈ្មោះអី?

រ៉ែម ៖ ឈ្មោះបងយ៉ង់ ថុល ខន និរតីទាំងអស់ ហើយស្អាតណាស់ពួកនឹង ។

ដានី ៖ ហើយកាចៗ?

រ៉ែម ៖ ហ៊ើ! កាច ។ បើប្រុសក្នុងភូមិចេះ ប្រុសវាស្អាតណា ស្អាតដូចប៉ុនវាត្រូវគ្នានឹងវានិរតី វាមានស្រឡាញ់ខ្លះ ។

ដានី ៖ មានមនោសញ្ចេតនាជាមួយ?

ប្តី ៖ អូ! មិនអស់ទេគ្នាវានោះ ។

រ៉ែម ៖ អាណាព្រមបានមកនិរតីៗនោះសៗស្កុះៗដូចចិន អត់មានខ្មៅទេ ស្អាតៗណាស់ឡើងភ្លឹងវាមិននេះទេ ។

ដានី ៖ ស្រីៗ?

រ៉ែម ៖ ចាំ! សុទ្ធតែស្រី ។

ដានី ៖ ចុះបើប្រុសៗស្អាតនឹង គាត់មកពីណា គាត់អ្នកធ្វើការនៅនឹង?

រ៉ែម ៖ បើសិន នៅនឹងភូមិយើងចេះ ដូចជាក្នុងភូមិយើងចេះ មានកម្លោះគេស្អាត អានោះវាចូលចិត្ត អាប្រុសនោះវាត្រូវបានស៊ីឆ្អែតជាមួយវាដែរ ។ វាបានបាយបានទឹកវាឲ្យស៊ី ។

ដានី ៖ ប៉ុន្តែអត់មានខុសសីលធម៌ជាមួយ?

រ៉ែម ៖ ទេ ។

ដានី ៖ ទោះគេមានចិត្តមានអីអត់ហ៊ាន?

រ៉ែម ៖ ចាំ! អត់ហ៊ានទេ ព្រោះមិនតែវាណា មានពីលើវាទៀត កាន់ក្តាប់ពីលើវាទៀត វាអត់ហ៊ានទេ ។

ដានី ៖ តែបើស្រីៗដូចគ្នា ដូចមីងអីគេអត់មាន អត់ត្រូវជាមួយ?

រ៉េម ៖ អត់ទេ លោកគ្រូ មានតែគេប្រើយើង ដែលត្រូវ ។

ដានី ៖ មានតែប្រុសស្អាតៗ គ្រាន់បើ?

រ៉េម ៖ ចាំ! គ្រាន់បើ បានដើរជាមួយស៊ីបាយជាមួយវាអីណា តែយើងស្រីៗមានទៅមើលមុខយើង មានតែពេលយកយើងទៅវ៉ៃចោល ។

ដានី ៖ តែបើប្រុសៗអត់មានមកៗខាងនិរតី?

រ៉េម ៖ មានៗខាងយោធា ។

ដានី ៖ ខាងយោធា?

រ៉េម ៖ ចាំ! ខាងយោធាគេដឹងកន្លែងណា បើពួកខ្ញុំមិនដែលបានទៅឃើញកន្លែងគេ ។

ដានី ៖ ចុះនៅកន្លែងអាងត្រពាំងថ្មនឹង មីងដឹងថាទំនប់ខ្ពស់ទំនប់នឹង ប៉ុនណាទទឹងវាប៉ុន្មានម៉ែត្រទៅ?

រ៉េម ៖ ទទឹងវាប៉ុន្មានដណ្តប់ម៉ែត្រ អាខ្ពស់លើវា ។

ដានី ៖ ប៉ុន្មានដណ្តប់?

រ៉េម ៖ ទេ! ធំណាស់ ។

ដានី ៖ ធំមែន?

រ៉េម ៖ ចាំ!ធំ ព្រោះយើងលើកចេះ យើងលើកវែកដីទៅ យើងចាក់លើវាចេះ ចាក់ពីលើចេះចាក់ ធ្វើខ្ពស់វាធំគ្រាន់ដែរ ធំ ធ្វើខ្ពស់វាឡើងខ្ពស់ ១២ម៉ែត្រនោះឯង ។

ដានី ៖ ចុះបណ្តោយប៉ុន្មាន?

រ៉េម ៖ បណ្តោយវាវែងគ្រាន់ដែរ.....(សម្លេងខ្សោយ) បើវាមិនដឹងប៉ុន្មានគីឡូ ឆ្ងាយ បើវាបត់បែនដែរ ទំនប់វា បត់វែង ។

ដានី ៖ អត់ដឹងប៉ុន្មាន?

រ៉េម ៖ ចុះមានប្រធានគេវាស់ ប៉ះណាបានទៅសួរគេ បើពួកខ្ញុំកូនក្រុម ដែលហ៊ានទៅសួរគេ?

ដានី ៖ ចុះអ្នកវាស់ពីណាគេប្រធាន?

រ៉េម ៖ អ្នកវាស់ប្រធានកងដូចគេផ្តាច់យើងផ្តាច់ការ ។

ដានី ៖ ឈ្មោះតាសេង ស្គាល់តាសេង?

រ៉េម ៖ សេង ភ្លេចហើយតាសេង ។

ដានី ៖ ភ្លេច?

រ៉េម ៖ ភ្លេចហើយតាសេង ។

ដានី ៖ ចុះពូសួយ ស្គាល់ពូសួយ?

រ៉េម ៖ ភ្លេចអស់ហើយ មើលតែនៅលើកទំនប់ជាមួយគ្នា ប្រជាជនថ្មីធ្លាប់ស្គាល់គ្នាល្អកល្អឿននៅតែភ្លេចគ្នាអស់ ។

ដានី ៖ ប្រជាជនថ្មី?

រ៉េម ៖ ចាំ! ប្រជាជនថ្មី មកពីភ្នំពេញមកអី ពីភ្នំពេញអីស្គាល់គ្នា ខេត្តតាកែវខ្ញុំធ្លាប់នៅនារីជាមួយគ្នាក៏ភ្លេចគ្នាអស់ ភ្លេចអស់ហើយលោកគ្រូ ។ ដល់យួនចូលក៏បែកបាក់ ភ្លេចអស់ ។

ដានី ៖ ចុះយាយថែមមិនដែលឃើញមុខគាត់ទេ?

រ៉េម ៖ អត់ដែលឃើញទេ ឮតែឈ្មោះគេឮនោះឯង បើឲ្យឃើញមិនដែលឃើញទេ ។

ដានី ៖ ចុះមីងរៀបការជាមួយពូឆ្នាំណា?

រ៉េម ៖ យួនចូលដឹងឆ្នាំណា ។

ដានី ៖ យួនចូលឆ្នាំ៧៩ ។

រ៉េម ៖ ចាំ!

ដានី ៖ ចុះពេលយួនចូល មីងអត់មានរត់ទៅតាមពួកខ្មែរក្រហម?

រ៉េម ៖ អត់ទេអត់បានទៅទេ រត់មកភូមិ រកម៉ែរកឪយើងវិញ ពួកវាក៏ទៅតាមគ្នាវា ទៅរថក្រោះជាន់សាប់ស្លាប់អស់ដឹង....(ស្តាប់មិនបាន) រថក្រោះតាមត្រឹកៗសង្ស័យមិនរស់ណា ។

ប្ដី ៖ មើលរត់ពីអាងជង្ហៀបក្ដាមនេះ រត់មកដល់ព្រៃមាន់យើងនេះវាក្បៀរមកពីនោះ វាដើរអមយោធាដើរអម ដល់មកដល់ឡានរថក្រោះវៀតណាមក៏វាគេចៗរត់តាមថ្នល់មកតាមរថក្រោះ ឲ្យដោះអាវខ្មៅចោល ។

រ៉េម ៖ រត់រកម៉ែរកឪលោកគ្រូអើយ វាក៏បំរាស់ទៅតែវា យើងក៏បំរាស់រកម៉ែរកឪយើងនេះ ។ អូ! តាស៊ីម ដែលសួរមិញ ។

ដានី ៖ តាស៊ីមនឹងគាត់ធ្វើអី?

រ៉េម ៖ តាស៊ីមនឹង ប្រធានសហករណ៍ខ្ញុំ ។

ដានី ៖ ឈ្មោះតាសេង?

រ៉េម ៖ តាសេង មិនមានទេ បើឈ្មោះតាស៊ីមស្គាល់ តាស៊ីមនោះស្គាល់ ស ប្រធានសហករណ៍គាត់នេះដែរខាងនិរតីដែរ ។

ដានី ៖ ចុះមីងនៅលើកចប់ពីទំនប់ត្រពាំងថ្មទៅលើកទំនប់?

រ៉េម ៖ កូនខ្វែង ។

ដានី ៖ កូនខ្មែរនឹងរហូតដល់វៀតណាមចូលម៉ង?

រ៉េម ៖ ទេ! អត់ទេ ព្រោះខ្ញុំលើកទៅ មកវិញដើរលើកតាមភូមនេះចល័តផ្សេងៗ បើខាងឪវាទៅខាងដង្កៀបក្តាម ។

ដានី ៖ ដល់ពេលវៀតណាមចូលហើយបានពូមីង រៀបការ?

រ៉េម ៖ ខ្ញុំទាល់តែខ្ញុំមកចូលភូមិវិញ កាលដែលយួនចូល ខ្ញុំអត់នៅភូមិក្នុងភូមិយើងនេះទេ ព្រោះវាចល័តឲ្យទៅនៅខាងនោះវិញ ។

ដានី ៖ នៅណា?

រ៉េម ៖ នៅខ្ញុំនៅតាប៉ែន ។

ដានី ៖ ភូមិតាប៉ែន?

រ៉េម ៖ ចា៎ៗ នៅតាប៉ែន ដល់ពួកខ្ញុំយួនចូលរួច ដល់ពេលយួនចូលបានយើងមករកផ្ទះក្នុងភូមិយើងនេះវិញមករកភូមិដើមវិញ ។

ដានី ៖ មករកភូមិដើមវិញឆ្នាំណា ៧៩ដដែល?

រ៉េម ៖ ចា៎! នេះឯង ។

ដានី ៖ ទៅមកបានជួបជាមួយពូរៀបការ?

រ៉េម ៖ ភូមិជាមួយគ្នា ។

ដានី ៖ រៀបការឆ្នាំ៧៩?

រ៉េម ៖ ចា៎! មិនទាន់មានលោកណា ដែលខ្ញុំការ ។

ប្តី ៖ ការទៅមេក្រុមអង្គុយរវៃដូចរម៉ូល ។ ចងដៃចងតែប្រាក់ ចងតែស្រូវ មាស ។

រ៉េម ៖ ស្រូវ យើងមិនទាន់មានប្រាក់ចាយផង ចាយមាស ។

ដានី ៖ ចឹងសម័យប៉ុលពតនឹង មានបាត់បងប្អូនមានស្លាប់?

រ៉េម ៖ ខ្ញុំនោះ មានស្លាប់ដោយសារជម្ងឺ បើរឿងយកទៅវៃចោលអត់មានទេ បើយើងបងប្អូនខ្ញុំដូចជាសំណាងវាសនាទៅទេវតាលោកជួយក៏បាននៅទល់ម្នាក់អត់មានអ្នកណាយកទៅវៃចោល ។

ដានី ៖ មីងខ្ញុំដូចជាអស់សំនួរអីត្រូវសួរនាំមីងទៀតហើយ មីងមានអីចង់បន្ថែមនូវអ្វីដែលខ្ញុំអត់បានសួរនាំទេ? ខ្ញុំភ្លេច មីងដឹងថាកំពស់ទំនប់ៗពីបាតទំនប់ រហូតដល់កំពូលនឹងប៉ុន្មានម៉ែត្រដែរទំនប់ត្រពាំងថ្ម?

រ៉េម ៖ ប៉ុន្មានម៉ែត្រ មិនបានទៅយើងលើកទំនប់ គួរតែដឹង ។

ដានី ៖ ចឹងយើងលើកឡើង តាមកាំជណ្តើរ?

វ៉េម ៖ អត់មានជណ្ដើរទេ ដល់ពេលយើងចាក់ចេះ យើងធ្វើថ្នាក់វាឡើងៗទៅចេះ ឡើងទៅលើអត់មានជណ្ដើរ យើងធ្វើថ្នាក់ត្រង់នេះអត់ដាក់ចោទទេ អាកន្លែងយើងឡើងអត់មានដាក់ចោទទេ យើងចាក់អាផ្សេងៗឲ្យចោទ ចាក់ឲ្យចោទត្រឹមដើងវាឲ្យចោទរួចបានយើងឈប់លើកនេះ បានយើងឈប់លើកនេះ បានយើងចាក់អាកន្លែងយើងលើក ។

ដានី ៖ យើងធ្វើប្រឡោះសម្រាប់ឡើង?

វ៉េម ៖ នោះឯង ។

ដានី ៖ ដល់ពេលយើងរែកអី បង្គីរ?

វ៉េម ៖ បង្គីរ ។

ដានី ៖ យើងដាក់ពេញៗ ហើយក៏?

វ៉េម ៖ ចា៎! ពេញ ធ្វើម៉េចឲ្យរួច យើងរែកដីដែលគេវាស់ឲ្យ យើងកាប់ខ្លួនយើង យើងរែកខ្លួនយើង ធ្វើម៉េចឲ្យតែរួចក្នុងម៉ាថ្ងៃ គ្មានពេលនេះទេ ។ ហើយយើងទៅធ្វើការចេះ តិចតែឃើញយើង អង្គុយម៉ាសន្ទុះចេះអត់បានទេ គេដើរត្រួតយើងចេះ ។

ដានី ៖ ពីណាអ្នកដើរ?

វ៉េម ៖ ពួកអង្គការនឹងឯង ប្រធានគេ ប្រធានអង្គការ ។

ដានី ៖ បើសិនជាយើងអង្គុយគេធ្វើម៉េច?

វ៉េម ៖ គេថាឲ្យ ។

ដានី ៖ គេថាម៉េច?

វ៉េម ៖ គេថាអត់ឲ្យយើងអង្គុយ អង្គការឲ្យជំរុញឲ្យឆាប់រួច មិនមែនអង្គការឲ្យមកនៅអង្គុយនៅអីទេ ចាំតែរួច ។

ប្ដី ៖ មហាលោតផ្លោះមហាអស្ចារ្យ ។

ដានី ៖ គេថាចឹង?

វ៉េម ៖ ចា៎!

ដានី ៖ ចឹងយើងអត់ហ៊ានអង្គុយ?

វ៉េម ៖ អត់ហ៊ានទេ ។

ដានី ៖ អ្នកធំៗគ្រាន់ដើរចឹង អត់មានរែកអីនឹងគេ?

រ៉េម ៖ ទេ! អត់ទេ បើគេប្រធានអត់មានបានរែកបានអីទេ គ្រាន់ដើរត្រួតតាមអន្លង់យើងចឹងឯង ក្រែងយើងនិយាយអី មានឈ្លបស៊ើបអី ក្រែងយើងថាយើងរែកចេះផង យើងនិយាយពីនេះពីនោះរឿងអីផ្សេងៗក៏មិនបាន យប់ឡើងដឹងថាបាត់ខ្លួនហើយ ។

ដានី ៖ ចុះដេកអីយើងដេកនៅនឹងដើងទំនប់នឹង ក៏មានរោងមានអី?

រ៉េម ៖ មានរោងគេ ។

ដានី ៖ គេធ្វើរោងនៅណា?

រ៉េម ៖ ធ្វើរោងឆ្ងាយពីទំនប់គ្រាន់ដែរ ធ្វើរោងឲ្យយើងដេក ។

ដានី ៖ ដេកនៅផ្ទាល់ដី ក៏មានគ្រែ?

រ៉េម ៖ ផ្ទាល់ដី ។

ដានី ៖ មានក្រាលកន្ទេលអីដែរ?

រ៉េម ៖ អត់មានទេ ។

ដានី ៖ យើងដេកដី?

រ៉េម ៖ បើយើងមានសំពត់កៅស៊ូយើងកាន់ដាប់ក្រាលខ្លួនយើងទៅ បើយើងមិនមានស្លឹកឈើទៅ យើងកាប់ស្លឹកឈើបានក៏ក្រាលដេក អីវ៉ាន់យើងក៏បង្កើរ ។

ដានី ៖ ចុះមានភួយអីដណ្តប់?

រ៉េម ៖ ភួយអត់ ខ្ញុំមិនមានទេ ។

ដានី ៖ អត់វងារអត់អី?

រ៉េម ៖ កាលនោះគេមានបើកឲ្យយើងណា អាយើងបើកសំពត់ខ្មៅឲ្យស្លៀកឲ្យទុក កន្លែងទទួលបន្ទាប់កន្លែង ។ ពេលវគ្គនេះ វាបើកឲ្យយើង កន្លែងមួយ អាវខ្មៅមួយ សំពត់ខ្មៅនេះមួយ ខោអាវខ្មៅ គេហៅខោអាវវាហៅស្តើ ខោអាវកប្បាស ជាផត្បាញធ្វើជាសំពត់ ហើយជ្រលក់ខ្មៅឲ្យយើងស្រេចៗ ។

ដានី ៖ ខោអាវម៉ាឆ្នាំគេបើកឲ្យប៉ុន្មានកំប្លេរ?

រ៉េម ៖ ក្នុងម៉ាឆ្នាំបើក មិនមែនម៉ាឆ្នាំទេ ២-៣កំប្លេរដឹងលោកគ្រូ រកវគ្គវា អង្គការចល័ត អង្គការណាឆាប់បើកឲ្យយើង ក្នុងម៉ាខែអីបើកឲ្យយើងម្តង ។

ប្តី ៖ កន្លែងអញម៉ាវគ្គចេះ រួមម៉ាទំនប់ចេះ គេបើកម៉ាកំប្លេរ ។

រ៉េម ៖ មិនបើកទេ ពួកយើងមិនដែលបើកផង ។

ប្តី ៖ មួយចល័តតំបន់ មួយចល័តឃុំ ចល័តតំបន់ ចល័តខេត្ត មួយចល័តតាមសហករណ៍ ។

ដានី ៖ បាទ! ចឹងមីងខ្ញុំអរគុណមីងច្រើនៗ

រ៉េម ៖ ចា៎!

«ចប់»